អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ប្រទេសស៊ុយអែដប្រកាសសន្យាផ្តល់ជំនួយថវិកាចំនួន ២៨ លានក្រោន ស្មើនឹងប្រមាណ ៤ លានដុល្លារអាមេរិក

ប្រទេសស៊ុយអែដបានប្រកាសសន្យាផ្តល់ជំនួយថវិកាចំនួន ២៨ លានក្រោន (ប្រមាណ ៤ លានដុល្លារអាមេរិក) ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់ការចំណាយឆ្នាំ ២០១២ និង ២០១៣ ទៅតាមគម្រោងថវិកាដែលបានអនុម័តរួចហើយ។ វិភាគទាននៃថវិកានេះគឺ ៥០% សម្រាប់ចំណាយក្នុងឆ្នាំ២០១២ ហើយ ៥០% ទៀតសម្រាប់ការចំណាយក្នុងឆ្នាំ២០១៣។

ឆ្លើយតបនឹងជំនួយសប្បុរសនេះ ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូសិនហក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានថ្លែងថា៖ “អ.វ.ត.ក សូមសម្តែងអំណរគុណដល់រដ្ឋាភិបាលស៊ុយអែដ ចំពោះជំនួយសប្បុរសនេះ ដែលផ្តល់ជូនក្នុងខណៈដែលភាគីអន្តរជាតិនៃ អ.វ.ត.ក កំពុងតែជួបប្រទះកង្វះខាតថវិកា។ ជំនួយនេះអនុញ្ញាតឲ្យ អ.វ.ត.ក អាចបន្តការងារដើម្បីបំពេញអាណត្តិរបស់ខ្លួនក្នុងការនាំយកយុត្តិធម៌ជូនប្រជាជនកម្ពុជា ដោយពុំមានការផ្អាកជាបន្ទាន់ណាមួយ”។

ថវិកាថ្មីនេះគឺជាជំនួយលើកទីពីររបស់រដ្ឋាភិបាលស៊ុយអែដ ចាប់តាំងពីការបង្កើត អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh